វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ១១ ខែ មករា ២០១៩**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការកើនឡើងនៃតម្លៃស្រូវ ជួយដល់កសិករកម្ពុជា
- អតិរេកគណនីចរន្តរបស់កូរ៉េខាងត្បូងមានការថយចុះ
- ការទាមទារសំណងនិកម្មភាពនៅសហរដ្ឋអាមេរិកមានការកើនឡើង

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការកើនឡើងនៃតម្លៃស្រូវជួយដល់កសិករកម្ពុជា

តម្លៃស្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានកើនឡើង ២៥ ភាគរយ សម្រាប់រដូវកាលដាំដុះឆ្នាំ២០១៨-២០១៩ បើយោងទៅតាមអ្នកធ្វើការក្នុងឧស្សាហកម្មស្រូវអង្ករ ដែលបានសម្ភាស៍ដោយភ្នំពេញប៉ុស្តិ៍។ តម្លៃស្រូវទទួលបានដោយកសិករក្នុងឆ្នាំនេះ គឺ ១ ៣០០រៀលក្នុងមួយគីឡូក្រាម ចំពោះប្រភេទស្រូវគុណភាពខ្ពស់ និង៩០០រៀលក្នុងមួយគីឡូក្រាម ចំពោះប្រភេទស្រូវធម្មតា។ កាលពីពេលមុន កសិករអាចរំពឹងតម្លៃប្រភេទស្រូវធម្មតាត្រឹមតែក្នុងចន្លោះពី ៥០០ទៅ ៦០០រៀលប៉ុណ្ណោះក្នុងមួយគីឡូក្រាម។

ការកើនឡើងនៃតម្លៃស្រូវ គឺដោយសារមានការកើនឡើងកាន់តែច្រើននូវចំនួនរោងម៉ាស៊ីនកិនស្រូវក្នុងតំបន់ លទ្ធភាពទាក់ទងទៅកាន់ឈ្មួញកណ្តាលសម្រាប់ទីផ្សារវៀតណាម និងការកើនឡើងនូវការធ្វើកសិកម្មតាមកិច្ចសន្យា។

### តារាងក្នុងសប្តាហ៍នេះ៖ សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស (Human Capital Index) សម្រាប់ប្រទេសក្នុងតំបន់អាស៊ាន

សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស(HCI)របស់ធនាគារពិភពលោក គឺតាមដានវឌ្ឍនភាពនៃលទ្ធផលការអប់រំ និងសុខភាព នៅក្នុងប្រទេសនានា។ សន្ទស្សន៍នេះវាស់វែងពីទំហំនៃការអភិវឌ្ឍធនធានមនុស្ស ដែលអាចរំពឹងថានឹងត្រូវបានបូកបង្គរ ដោយកុមារកើតក្នុងថ្ងៃនេះ ទៅដល់ត្រឹមអាយុ ១៨ឆ្នាំ ដែលនេះជាសូចនាករមានលក្ខណៈទូលំទូលាយមួយ បញ្ជាក់ពីផលិតភាពនៃកម្លាំងពលកម្មអ្នកជំនាន់ក្រោយរបស់ប្រទេសមួយ។

តារាងក្នុងសប្ដាហ៍នេះប្រៀបធៀបនូវសន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេសក្នុងអាស៊ាន។ សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេសសិង្ហបុរី ស្ថិតក្នុងលំដាប់កំពូលទាំងក្នុងចំនោមបណ្ដាប្រទេសអាស៊ាន និងទូទាំងសាកលលោក ក្នុងលំដាប់ពិន្ទុ០,៨៨។ កម្ពុជា គឺស្ថិតនៅក្រោមពាក់កណ្ដាលបណ្ដាប្រទេសក្នុងអាស៊ាន ក្នុងលំដាប់ពិន្ទុ០,៤៩ ដែលឈរនៅពីក្រោយវៀតណាម (០,៦៧) ម៉ាឡេស៊ី (០,៦២) ថៃ (០,៦០) និងហ្វីលីពីន (០,៥៥)។ ប៉ុន្តែកម្ពុជា ចិតក្នុងលំដាប់លើមីយ៉ាន់ម៉ា (០,៤៧) ឡាវ(០,៤៥) និង ទីម័រខាងកើត (០,៤៣) ។

### សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្សប្រទេសក្នុងតំបន់អាស៊ាន




ប្រភព៖ ធនាគារពិភពលោក

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អតិរេកគណនីចរន្តរបស់កូរ៉េខាងត្បូងមានការថយចុះ

យោងតាមរបាយការណ៍របស់ធនាគារកូរ៉េខាងត្បូង បានបង្ហាញថា អតិរេកគណនីចរន្តនៅក្នុងខែវិច្ឆិកាមានចំនួន ៥,០៦ ប៊ីលានដុល្លារ ដែលជាចំនួនទាបបំផុតចាប់តាំងពីខែមេសា ឆ្នាំ២០១៨។ តុល្យភាពនេះ មានការថយចុះពីអតិរេកចំនួន ៧,៤ ប៊ីលានដុល្លារ ក្នុងកំឡុងខែដូចគ្នាកាលពីឆ្នាំមុន។

អតិរេកគណនីទំនិញធ្លាក់ចុះរហូតទៅដល់ ៨,០ ប៊ីលានដុល្លារ ពី ១១,៥ ប៊ីលានដុល្លារក្នុងឆ្នាំមុន ដែលការនាំចេញមានការកើនឡើង ០,៥% និងការនាំចូលមានការកើនឡើង ៩,៣%។ គណនីសេវាកម្មមានឱនភាពចំនួន ២,៣ប៊ីលានដុល្លារ ធៀបនឹងឆ្នាំមុនមានចំនួន ៣,៣ ប៊ីលានដុល្លារ។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ការទាមទារសំណងនិកម្មភាពនៅសហរដ្ឋអាមេរិកមានការកើនឡើង

យោងតាមទិន្នន័យចុងក្រោយបំផុតមកពីក្រសួងការងារ បានឱ្យដឹងថា ការដាក់ពាក្យប្រកាសបឋមអំពីនិកម្មភាពបានកើនឡើងដល់ ២៣១ពាន់នាក់ នៅក្នុងសប្ដាហ៍ដែលបញ្ចប់នៅថ្ងៃទី ២៩ ខែធ្នូ ដែលមានការកើនឡើងចំនួន១០ពាន់នាក់ធៀបនឹងសប្ដាហ៍មុន។ លទ្ធផលនេះគឺខ្ពស់ជាងការរំពឹងទុករបស់ទីផ្សារ ដែលមានចំនួនត្រឹម ២២០ពាន់នាក់។

អត្រានិកម្មភាពដែលត្រូវបានកែសម្រួលតាមរដូវកាលសម្រាប់សប្ដាហ៍ដែលបញ្ចប់នៅថ្ងៃទី ២២ ខែធ្នូ មិនមានការផ្លាស់ប្ដូរពីសប្ដាហ៍មុនទេ ពោលគឺ១,២%។ នៅក្នុង ៤សប្ដាហ៍ ចំនួនជាមធ្យម នៃជនជាតិអាមេរិកដែលដាក់ពាក្យទទួលអត្ថប្រយោជន៍និកម្មភាពគឺមាន ២១៨ ៧៥០នាក់ ដែលទាបជាងសប្ដាហ៍មុនចំនួន ៥០០ នាក់ ។

## ព័ត៌មានសម្រាប់សប្ដាហ៍បន្ទាប់

ទិន្នន័យសង្ខេបសម្រាប់សប្ដាហ៍ខាងមុខនេះរួមមាន អតិផរណានៅក្នុងប្រទេសម៉ាឡេស៊ី តុល្យភាពពាណិជ្ជកម្ម និងការពិភាក្សាទៅលើអត្រាការប្រាក់របស់ឥណ្ឌូនេស៊ី ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុមFACT នឹងបន្តតាមដាននៅសប្ដាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ១៤ ខែមករា

- តុល្យភាពពាណិជ្ជកម្មនៅចិន សម្រាប់ខែធ្នូ

- ការវិនិយោគដោយផ្ទាល់ពីបរទេសនៅចិន សម្រាប់ខែធ្នូ
- អតិផរណារបស់អ្នកប្រើប្រាស់នៅអាមេរិក សម្រាប់ខែធ្នូ
- ភាពជឿជាក់របស់អ្នកប្រើប្រាស់នៅ តៃវ៉ាន់ សម្រាប់ខែធ្នូ

ថ្ងៃអង្គារ ទី ១៥ ខែមករា

- សន្ទស្សន៍នៃការបញ្ជាទិញរបស់អាមេរិក សម្រាប់ខែធ្នូ
- តម្លៃនៃការធ្វើពាណិជ្ជកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- តុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ខែធ្នូ
- អត្រានិកម្មភាពរបស់ម៉ាឡេស៊ី
- តុល្យភាពថវិការបស់បារាំង សម្រាប់ខែវិច្ឆិកា
- អតិផរណារបស់បារាំងសម្រាប់ខែធ្នូ
- តុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់ប្រ៊ុយណេ សម្រាប់ខែតុលា

ថ្ងៃពុធ ទី ១៦ ខែមករា

- ការបញ្ជាទិញម៉ាស៊ីនរបស់ជប៉ុន សម្រាប់ខែធ្នូ
- សន្ទស្សន៍នៃការបញ្ជាទិញរបស់ជប៉ុន សម្រាប់ខែធ្នូ
- អត្រាកំណើន ផសស របស់ប្រ៊ុយណេ សម្រាប់ត្រីមាសទី៣ឆ្នាំ ២០១៨
- សន្ទស្សន៍តម្លៃផ្ទះរបស់ចិន សម្រាប់ខែធ្នូ
- តម្លៃនៃការនាំចេញ នាំចូលរបស់អាមេរិក សម្រាប់ខែធ្នូ

ថ្ងៃព្រហស្បត្តិ៍ ទី ១៦ ខែមករា

- ការនាំចេញដែលមិនមែនប្រេងរបស់សិង្ហបុរី សម្រាប់ខែធ្នូ
- តុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់សិង្ហបុរី សម្រាប់ខែធ្នូ
- ការពិចារណាទៅលើអត្រាការប្រាក់របស់ឥណ្ឌូនេស៊ី
- អត្រានិកម្មភាពរបស់ហុងកុង សម្រាប់ខែធ្នូ
- ការប្រជុំ G20 របស់ជប៉ុន

ថ្ងៃសុក្រ ទី ១៧ ខែមករា

- ស្ថិតិអតិផរណារបស់ជប៉ុន សម្រាប់ខែធ្នូ
- ភាពជឿជាក់ទៅលើពាណិជ្ជកម្មរបស់ហុងកុង សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៨
- ផលិតកម្មឧស្សាហកម្មរបស់ជប៉ុន សម្រាប់ខែវិច្ឆិកា
- ការប្រើប្រាស់សមត្ថភាពឧស្សាហកម្មរបស់ចិន សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨